**សហព័ន្ធខ្មែរកម្ពុជាក្រោម**
KHMER KAMPUCHEA-KROM FEDERATION
ASIA – AUSTRALIA – EUROPE – NORTH AMERICA
KKF P.O. Box 0193 • Pennsauken • NJ 08110 • Tel: (856) 655-3838
http://www.khmerkrom.org • email: kampucheakrom@gmail.com

---

# សួស្តីឆ្នាំថ្មី ឆ្នាំ ២០១០

នាឱកាសឆ្នាំថ្មីចូលមកដល់ខាងមុខនេះ យើងខ្ញុំបាទសូមថ្លែងអំណរគុណ ចំពោះជនរួមឈាមទាំងនៅក្នុងស្រុក, នៅកម្ពុជា និងនៅជុំវិញពិភពលោក ដែលបានចូលរួមយ៉ាងសកម្មក្នុងចលនា ដើម្បីសិទ្ធិសេរីភាព និងផែនការដំណើរឆ្ពោះទៅកាន់មាតុភូមិ របស់សហព័ន្ធខ្មែរកម្ពុជាក្រោមនាឆ្នាំ ២០០៩។

សកម្មភាពកន្លងមក រួមមានផែនការ៣ខែ យ៉ាងសកម្ម និងមានប្រសិទ្ធិភាព បានជំរុញអោយរដ្ឋាភិបាលយួនភ័យខ្លាចនូវកម្លាំងសាមគ្គីខ្មែរនិងខ្មែរក្រោមនៅជុំវិញពិភពលោក។

ជាពិសេសភាពស្វិតស្វាញរបស់ជនរួមឈាមយើងនៅក្នុងស្រុក រួមនិងការគាំទ្រអន្តរជាតិ ដែលនាំអោយលោកគ្រូទឹម សាខន, គឹម មឿន, ដាញ ទូន, លី សឿង, លី ហ្វាង, ថាច់ ធឿង និងគ្រួសារលោកសឺន សារ៉ាង បានមកតាំងទីលំនៅប្រទេសទី៣។

ឆ្នាំ ២០០៩ ជាឆ្នាំដែលប្រវត្តិសាស្ត្រពិភពលោក និងខ្មែរក្រោមបានកត់ត្រានូវភាពរឹងត្អឹងរបស់រដ្ឋាភិបាលកុម្មុយនីស្តក្រុងហាណូយ ដែលបំពានយ៉ាងព្រៃផ្សៃ រំលោភសិទ្ធិមនុស្ស និងបង្ហាញនូវពុតត្បុតរបបអាណានិគមរបស់ខ្លួនមកលើម្ចាស់ស្រុក នៅថ្ងៃទី ៨ ខែឧសភា ចំពោះមុខក្រុមប្រឹក្សាសិទ្ធិមនុស្ស។

សាមគ្គីភាពប្រវត្តិសាស្ត្រ គឺមហាបាតុកម្មនៅមុខក្រុមប្រឹក្សាសិទ្ធិមនុស្ស នាទីក្រុងហ្សឺណែវ ដែលមានការចូលរួមពីសំណាក់ជនរួមឈាមខ្មែរយើងនៅទ្វីបអ៊ឺរ៉ុប, អាមេរិក, អូស្ត្រាលីនិងកម្ពុជាផងដែរ។

ទិវាខួបរំលឹកលើកទី ៦០ នៃការបាត់បង់ទឹកដីកម្ពុជាក្រោម នៅទីក្រុងហ្វិលីប៉ាំង ប្រទេសបារាំង នាថ្ងៃទី ១៣ ខែមិថុនា រំលឹកនូវអំពើអយុត្តិធម៌របស់រដ្ឋាភិបាលបារាំងសែស ដែលបានធ្វើសេចក្តីសំរេចប្រគល់ទឹកដីកម្ពុជាក្រោម អោយយួនបាវដាយ នាថ្ងៃទី ៤ ខែមិថុនា ឆ្នាំ១៩៤៩។

សហព័ន្ធខ្មែរកម្ពុជាក្រោម បានប្រមែប្រមូលនូវគតិ, យុទ្ធសាស្ត្រពីជនរួមឈាមជុំវិញពិភពលោកដាក់ជាផែនការ ហើយបានអនុវត្តតម្រូវតាមសេចក្តីត្រូវការខ្មែរក្រោម នៅក្នុងស្រុក ដែលជាជនរងគ្រោះពីរបបអាណានិគម។

សហព័ន្ធខ្មែរកម្ពុជាក្រោម បានរៀបរៀងនិងបោះពុម្ភសៀវភៅមគ្គុទេសក៍ពីរក្បាល៖ មួយជាភាសាខ្មែរ ចំណងជើងថា "***ផ្លូវទៅយកសិទ្ធិសំរេចវាសនាខ្លួន ដោយខ្លួនឯង***" មួយទៀតជាភាសាអង់គ្លេសចំណងជើងថា *"Khmer-Krom Journey to Self-Determination"*។

សហព័ន្ធខ្មែរកម្ពុជាក្រោម និងអនុវត្តនូវផែនការ ២០១០ យោងតាមសេចក្តីសំរេចអង្គប្រជុំប្រចាំឆ្នាំ នៅទីក្រុងសាន់ហូស្សេ រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក កាលពីថ្ងៃ ១២-១៣ ខែធ្នូ ឆ្នាំ ២០០៩។

សូមអោយឆ្នាំថ្មីនាំមកនូវសិរីសួស្តី សុភមង្គល វិបុលសុខ សាមគ្គីភាពខ្មែរនិងខ្មែរក្រោម ដើម្បីរក្សានូវព្រលឹងជាតិ មាតុភូមិជាទីស្នេហានៃយើង។

សូមជនរួមឈាមនៅក្នុងស្រុក និងជុំវិញពិភពលោក បានប្រកបតែពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សិទ្ធិជាម្ចាស់ស្រុកជាសិទ្ធិរបស់យើងជាខ្មែរក្រោម គ្មានជាតិសាសន៍ណា ឬជនណាអាចរំលោភនិងបំពានបានឡើយ សាមគ្គីដើម្បីប្រយោជន៍ជាតិ។

ធ្វើនៅសហរដ្ឋអាមេរិក, ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០០៩

ដោយគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំព្រះករុណាខ្ញុំបាទ

KHMERS KAMPUCHEA-KROM FEDERATION *** PRESIDENT ***

ថាច់ ង៉ុក ថាច់

ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម